01301741

E421/1

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះសាលាដំបូង |
| **ថ្ងៃដាក់** | : | ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 01-Jul-2016, 14:24
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សាធារណៈ**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

## សំណើរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងសក្ខីកម្មរបស់ជនជាប់ចោទ

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Marie GUIRAUD

**ចម្លងជូន:**

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

**សំណើ**

1. សហព្រះរាជអាជ្ញាកត់សម្គាល់ថា នៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹង *ដំណាក់កាលចុងក្រោយនៃសំណុំរឿង០០២/០២ - ការជូនដំណឹងអំពីកាលបរិច្ឆេទផ្សេងៗ*[1] មិនមានការអះអាងអំពីសក្ខីកម្មដែលអាចធ្វើដោយ នួន ជា និង ខៀវ សំផន ត្រូវបានធ្វើឡើងនោះទេ។ ខណៈដែលជនជាប់ចោទច្បាស់នៅដំណាក់កាលចុងបញ្ចប់នៃសំណុំរឿង០០២/០១ថា ពួកគាត់មិនមានចេតនាដាក់ការសួរដេញដោលដោយអង្គជំនុំជម្រះសាលាដំបូង ឬភាគីនានា នៅក្នុងសវនាការទេ សហព្រះរាជអាជ្ញាមិនបានដឹងអំពីការបញ្ជាក់ដាច់ស្រេចថា ពួកគាត់នឹងរក្សាទុកនូវគោលជំហរនេះរហូតដល់ចុងបញ្ចប់នៃសំណុំរឿង០០២/០២នោះទេ។ ក្នុងការរៀបចំសម្រាប់ដំណាក់កាលចុងក្រោយនៃសំណុំរឿង០០២/០២ និងអនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យជនជាប់ចោទជូនដំណឹងមកអង្គជំនុំជម្រះ និងភាគីទាំងឡាយ ប្រសិនបើពួកគេមានបំណងផ្តល់សក្ខីកម្ម ឬអនុវត្តសិទ្ធិរបស់ខ្លួនមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងក្នុងសំណុំរឿង០០២/០២ តាមកាលបរិច្ឆេទសមស្រប ដែលនឹងត្រូវកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង។ សហព្រះរាជអាជ្ញាយល់ឃើញថា ការទទួលបាននូវព័ត៌មានបែបនេះនឹងអនុញ្ញាតឱ្យអង្គជំនុំជម្រះ និងភាគីទាំងឡាយ មានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំសម្រាប់ការធ្វើសក្ខីកម្មបែបនោះ និងសម្រាប់ឱ្យអង្គជំនុំជម្រះកំណត់ពេលវេលាគ្រប់គ្រាន់សម្រាប់ធ្វើ ប្រសិនបើអង្គជំនុំជម្រះទទួលយកសំណើណាមួយបែបនោះ។

2. ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមស្នើថា អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យជនជាប់ចោទបញ្ជាក់ថាតើពួកគាត់មានបំណងផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២/០២ ឬអត់។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | [signature] |

[1] **E421** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពី "ដំណាក់កាលចុងក្រោយនៃសំណុំរឿង០០២/០២ - ការជូនដំណឹងអំពីកាលបរិច្ឆេទផ្សេងៗ", ២៨ មិថុនា ២០១៦។